ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

តុលាការរដ្ឋប្បវេណី

សំណុំរឿងលេខ ២០៤

ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២០

សាលក្រមលេខ ០១ "ខ"

ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០២១

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ឆ្នាំង

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០២១

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង

**ក្រឡាបញ្ជី**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំង

**ដើមចោទ**

ឈ្មោះ [redacted] សារឿន ភេទប្រុស អាយុ ៥៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរធ្វើស្រែ មានអាសយដ្ឋាន [redacted] ។

អ្នកតំណាងដោយអាណត្តិលោកមេធាវី [redacted] និងលោកមេធាវី [redacted] មានការិយាល័យក្រុមមេធាវី [redacted] និងសហការី មានអាសយដ្ឋាន [redacted] (បុរីសូទី) ។

**ចុងចម្លើយ**

ឈ្មោះ [redacted] ប៊ិន ភេទស្រី អាយុ ៥៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរធ្វើស្រែ មានអាសយដ្ឋាន [redacted] ។

អ្នកតំណាងដោយអាណត្តិលោកមេធាវី [redacted] មានការិយាល័យក្រុមមេធាវី [redacted] ផ្ទះលេខ ១A [redacted] ។

## អង្គហេតុ និងចំណុចវិវាទ

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ**

**ក.១. ការទាមទាររបស់ដើមចោទ**

១. សុំឈប់រស់នៅអនីតិសង្វាសពីចុងចម្លើយ

២. សុំសិទ្ធិគ្រប់គ្រងដីស្រែចំនួន ០៤កន្លែង និងផ្ទះសង់ឈើ ទំហំ ៧ម៉ែត្រ គុណនឹង ៨ម៉ែត្រ និងដីសង់ផ្ទះទំហំ ៤៧ ម៉ែត្រ គុណនឹង ៧៦ម៉ែត្រ

**ក.២. ការទាមទារក្នុងបណ្តឹងតបរបស់ចុងចម្លើយ**

១. សុំសិទ្ធិគ្រប់គ្រងដីស្រែចំនួន ០៤ កន្លែង និងផ្ទះសង់ឈើ ទំហំ ៧ ម៉ែត្រ គុណនឹង ៨ម៉ែត្រ និងដីសង់ផ្ទះទំហំ ៤៧ ម៉ែត្រ គុណនឹង ៧៦ម៉ែត្រ ។

២. ស្នើសុំឱ្យមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង ធ្វើការផ្ទេរនូវកម្មសិទ្ធិករលើដីស្រែ ០៤ កន្លែង មកឱ្យចុងចម្លើយឈ្មោះ **ឯក មិន** ដូចខាងក្រោម ៖

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៤០៦០៤០១-០០០១ ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១០

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៤០៦០៤០១-០១៣២ ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១០

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៤០៦០៤០៣-០៤៣២ ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០១០

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៤០៦០៤០៣-០០១៩ ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០១០

## ខ. ដំណើររឿងក្តី និងចំណុចវិវាទ

### ខ.១ ការសង្ខេបអំពីរឿងក្តី

ក្នុងរឿងក្តីនេះដើមចោទ ប្តឹងសុំលែងលះពីចុងចម្លើយដោយហេតុថា ខ្លួន និងចុងចម្លើយបានរៀបការតាមប្រពៃណីតាំងពីឆ្នាំ ១៩៨៦ តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នោះទេ ។ ក្នុងការរស់ជាមួយគ្នា ចុងចម្លើយតែងតែមានភាពរកាំរកូស មិនចុះសម្រុងនឹងគ្នា ទើបធ្វើឱ្យអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត។

### ខ.២ ចំណុចវិវាទ

តើដើមចោទពិតជាបានប្រគល់ដីស្រែចំនួន ៤កន្លែង និងដីផ្ទះមួយកន្លែងទៅឱ្យចុងចម្លើយ ស្របតាមកិច្ចព្រមព្រៀងចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៥ មែនដែរឬទេ?

### ខ.៣ ការអះអាងរបស់គូភាគី

#### ក. ការអះអាងរបស់ដើមចោទ

ដើមចោទបានធ្វើការអះអាងដូចមានក្នុងចំណុច ខ.១ (កាសង្ខេបអំពីរឿងក្តី) ក្នុងការរស់នៅជាមួយគ្នាខ្លួនមានទ្រព្យសម្បត្តិរួមដូចជា ផ្ទះសង់ឈើ ទំហំ ៧ ម៉ែត្រ គុណនឹង ៨ម៉ែត្រ និងដីសង់ផ្ទះទំហំ ៤៧ ម៉ែត្រ គុណនឹង ៧៦ម៉ែត្រ និងដីស្រែចំនួន ៤ កន្លែង រួមមាន ដីស្រែទី ១ ទំហំ ២.៧០ ហិចតា ដីស្រែទី ២ ទំហំ ១.៤០ ហិចតា ដីស្រែទី ៣ ទំហំ ៧០អា និងដីស្រែទី ៤ ទំហំ ៤០អា ស្ថិតនៅភូមិទួលខ្សាច់ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ ចំពោះផ្ទះសង់ឈើ ទំហំ ៧ ម៉ែត្រ គុណនឹង ៨ម៉ែត្រ និងដីសង់ផ្ទះទំហំ ៤៧ ម៉ែត្រ គុណនឹង ៧៦ម៉ែត្រ ខ្លួនព្រមព្រៀងប្រគល់ឱ្យចុងចម្លើយ ចំណែកដីស្រែ ០៤ កន្លែងសុំសិទ្ធិគ្រប់គ្រង ។

#### ខ. ការអះអាងរបស់ចុងចម្លើយ

ចំពោះការលែងលះខ្លួនមិនព្រមនោះទេ ខ្លួនសូមបដិសេធទៅលើការសុំសិទ្ធិគ្រប់គ្រងដីស្រែ ០៤ កន្លែង ស្ថិតនៅភូមិទួលខ្សាច់ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដោយហេតុថាខ្លួន និងដើមចោទបានធ្វើកិច្ចព្រមព្រៀង ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៥ នៅសាលាឃុំជ្រៃបាក់ ដោយដើមចោទ បានប្រគល់ដីស្រែ ០៤ កន្លែង ផ្ទះ និងដីសង់លំនៅឋានឱ្យខ្លួនរួចហើយ ហើយដើមចោទក៏បានទទួលចំណែកទ្រព្យសម្បត្តិដូចក្នុងកិច្ចព្រមព្រៀងរួចហើយ ។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា ៖



Scanned with CamScanner

១. ដើមចោទ និងចុងចម្លើយ ពិតជាបានរស់នៅជាមួយគ្នាជាអនីតិសង្វាសតាំងពីអំឡុងឆ្នាំ ១៩៨៦ ប្រាកដមែន ប៉ុន្តែពុំ បានចុះសំបុត្រអាពាហ៍ពិពាហ៍ទៅតាមច្បាប់ទេ ។

ការដែលគូភាគីមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍បែបនេះ គឺមានន័យថា គូភាគីមិនមានចំណង អាពាហ៍ពិពាហ៍នោះទេ គឺរស់នៅជាមួយគ្នាបែបអនីតិសង្វាសប៉ុណ្ណោះ ដែលគប្បីតុលាការសម្រេចឱ្យគូភាគី ឈប់រស់នៅជាមួយគ្នាជាអនីតិសង្វាស ។

២. ដោយគូភាគីមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ មានន័យថា គូភាគីពុំមានជាប់ចំណងអាពាហ៍ពិពាហ៍ តាមផ្លូវច្បាប់ឡើយ ដូច្នេះគូភាគីមានសិទ្ធិ និងសេរីភាពពេញលេញ ក្នុងការរៀបអាពាហ៍ពិពាហ៍តាមឆន្ទៈ របស់ខ្លួន ដោយភាគីម្ខាងទៀតគ្មានសិទ្ធិជំទាស់ឡើយ ។

៣. ចំពោះចំណុចវិវាទ តើដើមចោទពិតជាបានប្រគល់ដីស្រែចំនួន ៤កន្លែង និងដីផ្ទះមួយកន្លែងទៅឱ្យ ចុងចម្លើយ ស្របតាម កិច្ចព្រមព្រៀងចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៥ មែនដែរឬទេ? ចុងចម្លើយបានអះអាងថា ខ្លួន និងដើមចោទបានធ្វើកិច្ចព្រមព្រៀង ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៥ នៅសាលាឃុំជ្រៃបាក់ ដោយដើមចោទបានប្រគល់ដីស្រែ ០៤ កន្លែង ផ្ទះ និងដីសង់លំនៅឋានឱ្យខ្លួនរួចហើយ ហើយដើមចោទក៏បាន ទទួលចំណែកទ្រព្យសម្បត្តិដូចក្នុងកិច្ចព្រមព្រៀងរួចហើយ ចំណែកដើមចោទបានអះអាងថា ខ្លួនមិនបានធ្វើ កិច្ចព្រមព្រៀងដូចដែលចុងចម្លើយបានអះអាងទេ ខ្លួននៅតែសុំសិទ្ធិគ្រប់គ្រងដីស្រែ ០៤ កន្លែង និងផ្ទះសង់ឈើ ទំហំ ៧ ម៉ែត្រ គុណនឹង ៨ម៉ែត្រ និងដីសង់ផ្ទះទំហំ ៤៧ ម៉ែត្រ គុណនឹង ៧៦ម៉ែត្រ ដដែល ។

៤. ចម្លើយរបស់សាក្សីឈ្មោះ [redacted] ប៊ុនទត ជាមេឃុំជ្រៃបាក់ ដែលជាសាក្សីរបស់ចុងចម្លើយ បញ្ជាក់ថា ៖ ក្រោយទំនាស់ក្នុងគ្រួសារ ខ្លួនបានធ្វើការសម្របសម្រួលភាគីនៅតែមិនយល់ព្រម ក្រោយមកខាង អង្គការអាដហុក ធ្វើការសម្របសម្រួលបានយល់ព្រមលែងលះ និងយល់ព្រមយកលុយ ១លាន ឬក៏ ២លាន រៀល និងបានយល់ព្រមប្រគល់ទ្រព្យសម្បត្តិដីស្រែ ផ្ទះ និងបំណុលជំពាក់ធនាគារ ឱ្យចុងចម្លើយជាអ្នករ៉ាប់រង។ ចំពោះដីស្រែ ដើមចោទមិនយកទេ ព្រមទាំងផ្ទះ សុខចិត្តប្រគល់ឱ្យចុងចម្លើយ ។

៥. ចម្លើយរបស់សាក្សីឈ្មោះ [redacted] ពៅ ជាតំណាងសិទ្ធិនារីឃុំ ដែលជាសាក្សីរបស់ចុងចម្លើយបញ្ជាក់ថា ៖ ខ្លួនជាអ្នកទទួលកិច្ចការនារី និងជាជំទប់ទី១ ថ្នាក់មូលដ្ឋានបានតែសម្របសម្រួល ហើយគាត់បានសម្របសម្រួល ភាគី [redacted] សារឿន លុយពីរលានរៀល មាស ៥ជី ក្រៅពីនេះសុំឱ្យភាគីចុងចម្លើយជាអ្នកគ្រប់គ្រងចាត់ចែង ។ កិច្ចព្រមព្រៀងនេះគឺភាគីបានព្រមព្រៀងគ្នានៅអាដហុក នៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៥ ។ ក្រោយពីបាន ទទួលបានលទ្ធផលរួចហើយ គឺថាចំណែកជាការយល់ព្រម ហើយបានអានឱ្យស្តាប់ និងផ្តិតមេដៃ។

៦. ចម្លើយរបស់សាក្សីឈ្មោះ [redacted] សុភា ជាកូនបង្កើតរបស់ភាគីទាំងពីរ ហើយក៏ជាសាក្សីនៅក្នុង កិច្ចព្រមព្រៀង បញ្ជាក់ថា ៖ កាលនោះគាត់បានព្រមព្រៀងគ្នា ប៉ាបានយកលុយ ពីរលានរៀល មាស ៥ជី ម៉ូតូ អាសង់មួយគ្រឿង ដីមួយប្លង់ គាត់ចុះចេញ ។ ដីស្រែ ដីផ្ទះ ម៉ាក់ជាអ្នកគ្រប់គ្រងតាំងពីឆ្នាំ ២០១៥ ។

៧. តាមសំអាងហេតុខាងលើឃើញថា ទ្រព្យសម្បត្តិរួមរបស់ភាគីបានបែងចែក តាមរយៈកិច្ចព្រមព្រៀង ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៥ រួចហើយ គប្បីតុលាការសម្រេចច្រានចោលការទាមទាររបស់ដើមចោទ ។

៨. ចំពោះបណ្តឹងតបចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ២០២០ របស់ចុងចម្លើយឈ្មោះ [redacted] ម៉ិន ស្របនឹងការអះអាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដែលទាមទារ ដីស្រែចំនួន ០៤កន្លែង និងផ្ទះសង់ឈើ ទំហំ ៧ម៉ែត្រ គុណនឹង ៨ម៉ែត្រ និងដីសង់ ផ្ទះទំហំ ៤៧ ម៉ែត្រ គុណនឹង ៧៦ម៉ែត្រ គប្បីតុលាការសម្រេចតាមកិច្ចព្រមព្រៀងចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៥ ។

៦.ដើមចោទគប្បីទទួលបន្ទុកប្រាក់ប្រដាប់ក្តីចំនួន ៥៥.០០០ (ប្រាំម៉ឺនប្រាំពាន់) រៀល ដែលបានបង់រួចហើយ ។



Scanned with CamScanner

## ហេតុដូច្នេះសម្រេច

១. ឱ្យដើមចោទឈ្មោះ [redacted] សារឿន និងចុងចម្លើយឈ្មោះ [redacted] ប៊ិន ឈប់រស់នៅជាអនីតិសង្វាសជាមួយគ្នា ។

២. ប្រគល់ដីស្រែ ០៤ កន្លែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ៖

-លេខ ០៤០៦០៤០១-០០០១ ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១០

-លេខ ០៤០៦០៤០១-០១៣២ ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១០

-លេខ ០៤០៦០៤០៣-០៤៣២ ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០១០

-លេខ ០៤០៦០៤០៣-០០១៩ ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០១០

និង ផ្ទះសង់ឈើ ទំហំ ៧ ម៉ែត្រ គុណនឹង ៨ម៉ែត្រ និងដីសង់ផ្ទះទំហំ ៤៧ ម៉ែត្រ គុណនឹង ៧៦ម៉ែត្រ ស្ថិតនៅភូមិទួលខ្សាច់ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ឱ្យទៅចុងចម្លើយឈ្មោះ [redacted] ប៊ិន ។

៣. បង្គាប់ឱ្យមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង ធ្វើការផ្ទេរនូវកម្មសិទ្ធិករលើដី ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៤០៦០៤០១-០០០១ ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១០ លេខ ០៤០៦០៤០១-០១៣២ ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១០ លេខ ០៤០៦០៤០៣-០៤៣២ ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០១០ និងលេខ ០៤០៦០៤០៣-០០១៩ ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០១០ ដែលមានកម្មសិទ្ធិករឈ្មោះ [redacted] សារឿន និងឈ្មោះ [redacted] ប៊ិន ទៅជាឈ្មោះ [redacted] ប៊ិន ជាម្ចាស់កម្មសិទ្ធិវិញ ។

៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះ ត្រូវបានប្រកាសនៅសវនាការជាសាធារណៈនៅថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០២១ ។

ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ ។

ថ្ងៃពុធ ៦រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

កំពង់ឆ្នាំង, ថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០២១

**ចៅក្រម**

ហត្ថលេខា និងត្រា : [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៦រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

កំពង់ឆ្នាំង, ថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០២១

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]